# 13 시청 앞에서 일곱 시에 만나요
## ជួបគ្នានៅមុខសាលាក្រុងនាម៉ោង៧:០០

**학습 안내**
ការណែនាំអំពីមេរៀន

- □ **វត្ថុបំណងមេរៀន** ការកំណត់ពេលវេលានិងកន្លែងណាត់ជួប
- □ **វេយ្យាករណ៍** -고 싶다, -(으)ㄹ까요
- □ **ពាក្យថ្មី** ស្ថានភាពទី១, ស្ថានភាពទី២
- □ **ព័ត៌មាន · វប្បធម៌** ការសម្តែងការលាគ្នាតាមរយៈការសន្យាថានឹងណាត់ជួបគ្នាម្តងទៀតរបស់ជនជាតិកូរ៉េ

## 대화 1 ការសន្ទនា ១

Track 43



ខាងក្រោមនេះ គឺជាការសន្ទនារវាងធូអាន់និងស៊្សូរដែលនិយាយអំពីការសន្យាណាត់ជួបគ្នា។ សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**투안** 수루 씨, 내일 시간 있어요?
ស៊្សូរ, តើថ្ងៃស្អែកអ្នកមានពេលទំនេរដែរឬទេ?

**수루** 네, 시간 괜찮아요. 그런데 왜요?
ចា, ខ្ញុំមានពេល។ ប៉ុន្តែ មានរឿងអ្វីដែរ?

**투안** 우리 같이 영화 볼까요?
តើទៅមើលភាពយន្តជាមួយគ្នាដែរឬទេ?

**수루** 좋아요. 같이 영화 봐요.
ល្អណាស់។ ទៅមើលភាពយន្តជាមួយគ្នាបាន។
무슨 영화 볼까요?
តើនឹងមើលភាពយន្តបែបអ្វីដែរ?

**투안** 다 좋아요. 수루 씨는 뭐 보고 싶어요?
ភាពយន្តបែបអ្វីក៏ល្អដែរ។ ចុះស៊្សូរវិញ ចង់មើលភាពយន្តបែបអ្វី?

**수루** 코미디 영화를 보고 싶어요.
ខ្ញុំចង់មើលភាពយន្តបែបកំប្លែង។

> **그런데 왜요? ប៉ុន្តែ មានរឿងអ្វីដែរ?**
> ប្រើប្រាស់ដើម្បីសួររកមូលហេតុដែលទាក់ទងជាមួយនឹងសំណួរដែលបានសួរមកពីខាងមុខ។
> · 내일은 바빠요. 그런데 왜요?
> ថ្ងៃស្អែកខ្ញុំរវល់។ ប៉ុន្តែមានរឿងអ្វីដែរ?

> **무슨 N តើ…… …អ្វី?**
> ប្រើប្រាស់នៅខាងមុខ"នាម"ដើម្បីសាកសួរអំពីអ្វីមួយ។
> · 무슨 음식을 잘 만들어요?
> តើអ្នកពូកែធ្វើម្ហូបអ្វី?



តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 수루 씨는 내일 시간이 있어요? តើថ្ងៃស្អែកស៊្សូរមានពេលទំនេរដែរឬទេ?
2. 투안 씨는 내일 뭐 해요? តើថ្ងៃស្អែកធូអាន់នឹងធ្វើអ្វី?

정답 1. 네, 시간이 있어요./네, 시간이 괜찮아요. 2. 수루 씨하고 같이 영화를 봐요.

## 어휘 1 ពាក្យថ្មី ១ | 상태 1 ស្ថានភាពទី១



យើងនឹងស្វែងយល់អំពីគុណនាមខ្លះៗនៅក្នុងស្ថានភាពទី១នេះជាមួយគ្នា។



시간(이) 있다
មានពេលទំនេរ



시간(이) 없다
គ្មានពេលទំនេរ



약속(이) 있다
មានការសន្យាណាត់ជួបហើយ



약속(이) 없다
អត់មានការសន្យាណាត់ជួបទេ



일이 많다
មានការងារច្រើនណាស់



일이 적다
មានការងារបន្តិចបន្តួច



바쁘다
រវល់



한가하다
មិនសូវរវល់



재미있다
ល្អមើល



재미없다
មិនល្អមើល



좋다
ល្អណាស់



괜찮다
មិនអីទេ



សូមកុំមើលពាក្យដែលនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 단어를 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

㉠ 재미있다　㉡ 재미없다　㉢ 바쁘다　㉣ 한가하다

정답 ①㉢ ②㉣ ③㉠ ④㉡

## 문법 1 វេយ្យាករណ៍ ១ | -고 싶다

G13-1

យើងប្រើប្រាស់ '-고 싶다' ភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនឯងចង់ធ្វើអ្វីមួយ។ វាត្រូវបានប្រើប្រាស់ជាប្រយោគសំណួរ ដើម្បីសួរអំពីចំណាប់អារម្មណ៍របស់អ្នកដទៃថាគេចង់ធ្វើអ្វី។ ទោះបីកិរិយាស័ព្ទដែលត្រូវភ្ជាប់ជាមួយ '고 싶다' មានជើងរឺក៏គ្មានជើងក៏ដោយ យើងប្រើប្រាស់៖ កិរិយាស័ព្ទ+ '-고 싶다' ទាំងអស់។

- 영화를 **보고 싶어요**. ខ្ញុំចង់មើលភាពយន្ត។
- 가: 뭐 **먹고 싶어요**? តើអ្នកចង់ហូបអ្វី?
  나: 비빔밥을 **먹고 싶어요**. ខ្ញុំចង់ហូបពីពីមប៉ាប់។



តើអ្នកយល់អំពីការប្រើប្រាស់'-고 싶다'ហើយមែនដែរឬទេ? អញ្ចឹងសូមមើលរូបភាព បន្ទាប់មកចូរបញ្ចប់ការឆ្លើយតបឲ្យបានត្រឹមត្រូវទៅនឹងសំណួរ។

2. 그림을 보고 〈보기〉처럼 '-고 싶다'를 사용해서 대화를 완성하세요.
   សូមមើលរូបភាព ហើយចូរប្រើប្រាស់'-고 싶다'មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 뭐 하고 싶어요? តើអ្នកចង់ធ្វើអ្វី?
나: 영화를 보고 싶어요. ខ្ញុំចង់មើលភាពយន្ត។

1) 

가: 뭐 하고 싶어요?
나: ______________________.

2) 

가: 뭐 하고 싶어요?
나: ______________________.

3) 

가: 뭐 하고 싶어요?
나: ______________________.

4) 

가: 뭐 하고 싶어요?
나: ______________________.

정답 1) 노래하고 싶어요 2) 산책하고 싶어요 3) 쇼핑하고 싶어요 4) 커피를 마시고 싶어요

## 유용한 표현 កន្សោមពាក្យសំខាន់ៗ

### 내일 뵙겠습니다. ថ្ងៃស្អែកជួបគ្នា។

가: 지금 퇴근하세요? 조심해서 가요. ពេលនេះចេញពីធ្វើការហើយឬ? សូមធ្វើដំណើរដោយប្រយ័ត្នប្រយែង។
나: 네, 반장님. **내일 뵙겠습니다.** បាទ/ចា, លោកប្រធានក្រុម។ ថ្ងៃស្អែកជួបគ្នា។

## 대화 2 ការសន្ទនា ២

Track 44



ធូអាន់និងស៊ូរ៉ូកំពុងនិយាយអំពីការសន្យាណាត់ជួបគ្នា។ ដំបូង សូមស្ដាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

**투안** 우리 내일 어디에서 만날까요?
តើថ្ងៃស្អែកពួកយើងនឹងជួបគ្នានៅឯណា?

**수루** 시청 앞 어때요?
ជួបគ្នានៅមុខសាលាក្រុងយ៉ាងម៉េចដែរ?

**투안** 좋아요. 그러면 여섯 시쯤 만날까요?
ល្អ។ បើអញ្ចឹង យើងជួបគ្នានៅល្ងាក់ម៉ោង៦:០០ ជាងបន្តិចល្អដែររឺទេ?

**수루** 여섯 시는 좀 빨라요.
ម៉ោង៦:០០គឺរាងឆាប់បន្តិចហើយ។
일곱 시에 괜찮아요?
ចុះម៉ោង៧:០០វិញយ៉ាងម៉េចដែរ?

**투안** 네, 괜찮아요. បាទ, គ្មានបញ្ហាទេ។
그럼 내일 시청 앞에서 일곱 시에 봐요.
អញ្ចឹង ថ្ងៃស្អែកយើងជួបគ្នានៅមុខសាលាក្រុងនាម៉ោង៧:០០។

> **어때요? យ៉ាងម៉េចដែរ?**
> យើងប្រើប្រាស់ប្រយោគនេះ ដើម្បីសួរអំពីមតិយោបល់របស់ដៃគូសន្ទនាទៅលើវត្ថុបំណងអ្វីមួយ។
> - 이 구두 어때요?
>   តើស្បែកជើងមួយគូនេះ យ៉ាងម៉េចដែរ?
> - 내일 여섯 시 어때요?
>   ថ្ងៃស្អែកម៉ោង៦:០០យ៉ាងម៉េចដែរ?

> **N쯤 ល្ងាក់+នាម**
> យើងប្រើប្រាស់ទម្រង់នេះជាមួយនាម សម្រាប់និយាយអំពីកំឡុងពេលណាមួយនៃពេលវេលា។
> - 주말쯤 만나서 같이 영화 볼까요?
>   ល្ងាក់ចុងសប្ដាហ៍នេះទៅមើលភាពយន្តជាមួយគ្នាដែរឬទេ?
> - 12월 말쯤 고향으로 돌아가려고 해요.
>   ល្ងាក់ចុងខែធ្នូនេះ ខ្ញុំមានបំណងចង់វិលត្រឡប់ទៅស្រុកកំណើតវិញ។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨하고 수루 씨는 어디에서 만나요? តើធូអាន់និងស៊ូរ៉ូជួបគ្នានៅកន្លែងណា?
2. 두 사람은 몇 시에 만나요? តើអ្នកទាំង២ជួបគ្នានៅម៉ោងប៉ុន្មាន?

**정답** 1. 시청 앞에서 만나요. 2. 일곱 시에 만나요.

### Tip 관공서 ទីស្នាក់ការសាធារណៈ



도청
សាលាខេត្ត



시청
សាលាក្រុង



구청
សាលាសង្កាត់



경찰서
ទីស្នាក់ការប៉ូលីស



소방서
ស្ថានីយ៍ពន្លត់អគ្គីភ័យ



출입국관리사무소
ការិយាល័យអន្តោប្រវេសន៍



보건소
មណ្ឌលសុខភាពសាធារណៈ



주민센터
មជ្ឈមណ្ឌលសហគមន៍

## 어휘 2 ពាក្យថ្មី ២ | 상태 2 ស្ថានភាពទី២



យើងនឹងស្វែងយល់អំពីគុណនាមខ្លះៗនៅក្នុងស្ថានភាពទី២នេះជាមួយគ្នា។

| | | | |
|---|---|---|---|
|   빠르다(이르다) លឿន(ហើស) |   늦다 យឺត |  가깝다 ជិត |  멀다 ឆ្ងាយ |
|  같다 ដូចគ្នា |  다르다 ខុសគ្នា |   간단하다 ងាយស្រួល |   복잡하다 ស្មុគស្មាញ |
|  편하다 មានផាសុខភាព |  불편하다 មិនមានផាសុខភាព |  가능하다 អាច |  불가능하다 មិនអាច |

### ទម្រង់មិនទៀងទាត់ ‘ㄹ’

ពាក្យណាមួយដែលបញ្ចប់ទៅដោយ ‘ㄹ’ នៅពេលដែលវាជួបនឹងស្រៈមួយទៀត, ពេលនោះជើងព្យញ្ជនៈ‘ㄹ’ត្រូវបញ្ចូលទៅខាងក្រោមពាក្យដើម ហើយចំណែកឯស្រៈ‘ㅡ’ វិញ ត្រូវបានលុបចោល។

예) · 빠르(다) + 아요 = 빨라요　　· 이르(다) + 어요 = 일러요



សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកចូរសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 단어를 연결하세요. សូមមើលរូបភាព បន្ទាប់មកមកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 　② 　③ 　④ 

㉠ 멀다　㉡ 같다　㉢ 다르다　㉣ 가깝다

정답 ① ㉣ ② ㉠ ③ ㉡ ④ ㉢

## 문법 2 វេយ្យាករណ៍ ២ | -(으)ㄹ까요

G13-2

យើងប្រើប្រាស់ '-(으)ㄹ까요' ភ្ជាប់ជាមួយកិរិយាស័ព្ទ ដើម្បីផ្តល់ជាយោបល់អ្វីមួយទៅដៃគូសន្ទនា ឬក៏ស្នើសុំអោយធ្វើអ្វីមួយជាមួយគ្នា។

| 자음(ព្យញ្ជនៈ) → **-을까요** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → **-ㄹ까요** |
|---|---|
| 읽다 → 읽**을까요** | 사다 → **살까요**<br>만들다 → 만**들까요** |

- 가: 몇 시에 **만날까요**? តើនឹងជួបគ្នានៅម៉ោងប៉ុន្មាន?
  나: 7시에 만나요. ជួបគ្នានៅម៉ោង៧:០០។
- 가: 내일 같이 점심 **먹을까요**? តើថ្ងៃស្អែកហូបអាហារថ្ងៃត្រង់ជាមួយគ្នាដែរឬទេ?
  나: 좋아요. 같이 점심 먹어요. ល្អ។ ថ្ងៃស្អែកហូបអាហារថ្ងៃត្រង់ជាមួយគ្នាបាន។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ រវាង '-(으)ㄹ까요' និង '-(으)ㄹ래요' (មេរៀនទី១៤)**

ការប្រើប្រាស់ '-(으)ㄹ까요' និង '-(으)ㄹ래요' មានភាពស្រដៀងគ្នា។ ដូចគ្នាត្រង់ថា ទម្រង់ទាំង២នេះប្រើប្រាស់ដើម្បីសួររកអំពីចេតនា ឬក៏មតិយោបល់របស់ដៃគូសន្ទនាដូចគ្នា។ ខុសគ្នាត្រង់ថា '-(으)ㄹ래요' មិនអាចប្រើប្រាស់ជាមួយមនុស្សដែលមានឋានៈខ្ពស់ជាងយើងបានឡើយ។ ក្នុងករណីមនុស្សដែលមានឋានៈខ្ពស់ជាងយើងក៏ពិតមែន ប៉ុន្តែមានភាពជិតស្និទ្ធគ្នានោះ យើងអាចប្រើប្រាស់ '-(으)ㄹ까요' បាន។

- 부장님, 몇 시에 갈래요? (X)
- 부장님, 몇 시에 **갈까요**? (O)



តើអ្នកយល់អំពីការប្រើប្រាស់ទម្រង់វេយ្យាករណ៍'-(으)ㄹ까요'ហើយមែនដែរឬទេ? អញ្ចឹងសូមបំពេញការសន្ទនាខាងក្រោមនេះឲ្យបានត្រឹមត្រូវ។

2. 〈보기〉처럼 '-(으)ㄹ까요'를 사용해서 대화를 완성하세요.
   សូមប្រើប្រាស់ '-(으)ㄹ까요' មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

**보기**
가: 오늘 같이 점심 먹을까요? តើថ្ងៃនេះហូបអាហារថ្ងៃត្រង់ជាមួយគ្នាដែរឬទេ?
나: 좋아요. 같이 점심 먹어요. ល្អ។ ហូបអាហារថ្ងៃត្រង់ជាមួយគ្នាបាន។

1) 가: 저녁에 같이 ____________?
   나: 좋아요. 같이 영화 봐요.

2) 가: 지금 같이 커피 한잔 ____________?
   나: 미안해요. 지금 너무 바빠요.

3) 가: 오늘 몇 시에 ____________?
   나: 7시 어때요?

4) 가: 우리 내일 뭐 ____________?
   나: 같이 운동해요.

정답 1) 영화 볼까요 2) 마실까요 3) 만날까요 4) 할까요



រៀនថែមបន្តិចទៀតតើល្អដែរឬទេ? ចូរសាកល្បងប្រើប្រាស់'-(으)ㄹ까요'មកបញ្ចប់ការសន្ទនា។

1) 가: 저녁에 같이 시내에 ____________?
   나: 좋아요. 같이 시내에 가요.

2) 가: 주말에 같이 한국어를 ____________?
   나: 좋아요. 같이 공부해요.

정답 1) 갈까요 2) 공부할까요

## 활동 សកម្មភាព

〈보기〉처럼 친구와 이야기해 보세요. សូមសាកល្បងនិយាយជាមួយមិត្តភក្តិដូច<ឧទាហរណ៍>។

보기

| | |
|---|---|
| 가: 리한 씨, 우리 같이 극장에 갈까요? | រីហាន់, តើទៅរោងភាពយន្តជាមួយគ្នាដែររឺទេ? |
| 나: 좋아요. 같이 가요. | ល្អ។ ទៅជាមួយគ្នាបាន។ |
| 가: 극장에서 무슨 영화를 볼까요? | តើនឹងមើលភាពយន្តបែបអ្វីពេលទៅដល់រោងភាពយន្ត? |
| 나: 코미디 영화 어때요? | ភាពយន្តបែបកំប្លែងយ៉ាងម៉េចដែរ? |
| 가: 좋아요. 그러면 몇 시에 만날까요? | ល្អ។ បើអញ្ចឹង តើយើងនឹងជួបគ្នានៅម៉ោងប៉ុន្មាន? |
| 나: 저녁 7시에 만나요. | ជួបគ្នានៅម៉ោង៧:០០ល្ងាច។ |
| 가: 어디에서 만날까요? | តើនឹងជួបគ្នានៅឯណា? |
| 나: 회사 앞에서 만나요. | ជួបគ្នានៅមុខក្រុមហ៊ុន។ |

| | 보기 리한 씨 | ________ 씨 |
|---|---|---|
| 어디에 가요?<br>តើអ្នកទៅណា? | 극장<br>រោងភាពយន្ត | |
| 뭐 해요?<br>តើអ្នកធ្វើអ្វី? | 코미디 영화를 봐요.<br>មើលភាពយន្តបែបកំប្លែង។ | |
| 언제 만나요?<br>តើជួបគ្នានៅពេលណា? | 저녁 7시<br>ម៉ោង៧:០០ល្ងាច | |
| 어디에서 만나요?<br>តើជួបគ្នានៅឯណា? | 회사 앞<br>នៅមុខក្រុមហ៊ុន | |



សូមមើល<ឧទាហរណ៍>ខាងលើ ហើយសាកល្បងឆ្លើយនឹងសំណួរខាងក្រោម។

✚ 알맞은 말에 ✓하세요. សូមគូសសញ្ញា ✓ ទៅលើចម្លើយដែលត្រឹមត្រូវ។

(1) 리한 씨는 ☐ 공포 영화를 봅니다. ☐ 코미디 영화를 봅니다.

(2) 리한 씨는 ☐ 극장 앞에서 친구를 만납니다. ☐ 회사 앞에서 친구를 만납니다.

(3) 리한 씨는 일곱 시에 ☐ 영화를 봅니다. ☐ 친구를 만납니다.

정답 (1) 코미디 영화를 봅니다. (2) 회사 앞에서 친구를 만납니다. (3) 친구를 만납니다.

## 문화 អំពីវប្បធម៌

# 한국 사람들이 인사로 하는 약속

### ការសម្តែងការលាគ្នាតាមរយៈការសន្យាថានឹងណាត់ជួបគ្នាម្តងទៀតរបស់ជនជាតិកូរ៉េ




한국 사람들은 헤어질 때 “다음에 밥 한번 같이 먹어요.”, “술 한잔 같이 해요.”라는 인사를 하기도 합니다. 특히 헤어질 때 “연락할게.”라는 말도 자주 하는데, 이런 말들은 약속이라기보다는 헤어지기 아쉬워서 하는 말인 경우가 많습니다. 구체적으로 날짜와 시간을 약속하지 않을 경우에는 가벼운 인사로 생각하는 것이 좋습니다. 만약에 한국사람들이 “언제든지 연락하세요.”라고 말했더라도 너무 이른 시간이나 늦은 시간, 그리고 식사 시간이나 휴식 시간에는 연락을 피하는 것이 좋습니다. 또한 “언제든지 놀러 오세요.”라고 말했더라도 전화로 미리 약속을 하고 만나러 가는 것이 좋습니다.

ជនជាតិកូរ៉េ នៅពេលដែលលាគ្នា គេតែងតែនិយាយថា៖ "លើកក្រោយហូបបាយជាមួយគ្នាម្តង" ឬក៏"ចាំផឹកស្រាជាមួយគ្នាម្តង"ជាដើម។ ជាពិសេសល្បះមួយដែលនិយាយថា៖ "ខ្ញុំនឹងទាក់ទងទៅ។"ក៏ឧស្សាហ៍ប្រើប្រាស់ញឹកញាប់ណាស់ដែរ។ ល្បះដែលបានរៀបរាប់ដូចខាងលើនេះ ស្តាប់មើលទៅដូចជាការសន្យាថានឹងណាត់ជួបគ្នាមែនទែនអញ្ចឹង ប៉ុន្តែវាបានបង្ហាញអំពីការមិនអស់ចិត្តដែលត្រូវដល់ពេលលាគ្នាទៅវិញនោះទេ។ ប្រសិនបើដៃគូសន្ទនា មិនបានកំណត់អំពីទីកន្លែងនិងពេលវេលាច្បាស់លាស់នោះទេ ចាត់ទុកថាវាគ្រាន់តែជាការលាគ្នាធម្មតាតែប៉ុណ្ណោះ។ មួយវិញទៀត ប្រសិនបើមានជនជាតិកូរ៉េនិយាយថា៖ "អាចទាក់ទងមកខ្ញុំនៅពេលណាក៏បាន។"នោះ យកល្អ អ្នកមិនគួរទំនាក់ទំនងទៅគេនៅពេលព្រឹកព្រលឹមពេក ឬក៏នៅពេលយប់ជ្រៅពេកនោះទេ, ទោះបីម៉ោងអាហារថ្ងៃត្រង់និងម៉ោងសម្រាកក៏ដោយក៏មិនគួរទំនាក់ទំនងទៅគេដែរ។ ម្យ៉ាងទៀត នៅពេលដែលគេនិយាយថា៖ "មកលេងខ្ញុំនៅថ្ងៃណាក៏បាន។"វិញ ប្រសិនបើអ្នកមានបំណងចង់ទៅសួរសុខទុក្ខគេមែន គួរតែទូរស័ព្ទឬក៏សុំណាត់ជាមួយគេទុកជាមុន ទើបជាការប្រសើរ។

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK

សំណួរទី១និងទី២ គឺជាការជ្រើសរើសយកពាក្យដែលអ្នកបានស្តាប់លឺ។ សូមស្តាប់ដោយយកចិត្តទុកដាក់ ហើយជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

[1~2] 들은 것을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលអ្នកបានស្តាប់លឺ។

Track 45

1. ① 내일　　② 영화　　③ 시간　　④ 극장

2. ① 도청　　② 시장　　③ 구청　　④ 시청

បន្ទាប់ទៅនេះគឺជាការស្តាប់ការនិយាយ រួចហើយចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។ មុននឹងស្តាប់ការសន្ទនា សូមពិនិត្យមើលខ្លឹមសាររបស់សំណួរម្តងជាមុនសិន។

[3~5] 이야기를 듣고 질문에 알맞은 대답을 고르십시오.
សូមស្តាប់ការនិយាយ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។

3. 두 사람은 내일 같이 무엇을 봅니까? តើនៅថ្ងៃស្អែកអ្នកទាំងពីរមើលអ្វីជាមួយគ្នា?
① 책　　② 사진
③ 영화　　④ 드라마

4. 두 사람은 내일 어디에서 만납니까? តើថ្ងៃស្អែកអ្នកទាំងពីរជួបគ្នានៅឯណា?
① 극장 앞　　② 회사 앞
③ 백화점 앞　　④ 도서관 앞

5. 두 사람은 내일 몇 시에 만납니까? តើថ្ងៃស្អែកអ្នកទាំងពីរជួបគ្នានៅម៉ោងប៉ុន្មាន?
① 6시　　② 7시
③ 8시　　④ 9시



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្ដាប់

1. 남: 영화 ភាពយន្ត
2. 여: 시청 សាលាក្រុង
3. 남: 우리 내일 같이 영화 볼까요? តើថ្ងៃស្អែកទៅមើលភាពយន្តជាមួយគ្នាដែរឬទេ?
   여: 좋아요. 같이 봐요. ល្អ។ ទៅមើលភាពយន្តជាមួយគ្នាបាន។
4. 남: 우리 내일 어디에서 만날까요? តើថ្ងៃស្អែកពួកយើងនឹងជួបគ្នានៅឯណា?
   여: 백화점 앞에서 볼까요? ជួបគ្នានៅមុខផ្សារទំនើបល្អដែរឬទេ?
   남: 좋아요. 거기에서 만나요. ល្អ។ ថ្ងៃស្អែកជួបគ្នានៅទីនោះ។
5. 남: 내일 7시에 만날까요? តើថ្ងៃស្អែកពួកយើងនឹងជួបគ្នានៅម៉ោង៧:០០ល្អដែរឬទេ?
   여: 7시는 좀 힘들어요. 8시는 어때요? ថ្ងៃស្អែកម៉ោង៧:០០ រាងពិបាកបន្តិចហើយ។ ចុះម៉ោង៨:០០វិញយ៉ាងម៉េចដែរ?
   남: 좋아요. 그럼 8시에 만나요. ល្អ។ អញ្ចឹងជួបគ្នានៅម៉ោង៨:០០វិញក៏បានដែរ។

정답 1. ② 2. ④ 3. ③ 4. ③ 5. ③

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-13

1. 잘 듣고 내용과 관계있는 그림을 고르십시오.
   សូមស្ដាប់ដោយយកចិត្តទុកដាក់ បន្ទាប់មកចូរជ្រើសរើសរូបភាពដែលទាក់ទងទៅនឹងខ្លឹមសារ។

①


②


③


④


2. 질문을 듣고 알맞은 대답을 고르십시오. សូមស្ដាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

   ① 오늘 만나요. ② 은행 앞 어때요?
   ③ 세 명이 만나요. ④ 두 시에 만날까요?

## 확장 연습 듣기 대본 អត្ថបទស្ដាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 의자가 불편해요.កៅអីនេះមិនមានផាសុខភាពសោះ។
2. 남: 어디에서 만날까요? តើនឹងជួបគ្នានៅឯណា?

정답 1. ③ 2. ②

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



សំណួរទី១និងទី២ សូមអានការសន្ទនា រួចហើយជ្រើសរើសយកចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។ សូមរំលឹកអំពីអ្វីដែលអ្នកបានរៀនរួចហើយមកនោះឡើងវិញ និងធ្វើការដោះស្រាយសំណួរបណ្ដើរ។

[1~2] 다음 질문에 답하십시오. សូមឆ្លើយសំណួរខាងក្រោម។

1. 두 사람은 지금 무엇을 하고 있습니까? តើពេលនេះអ្នកទាំងពីរកំពុងតែធ្វើអ្វី?

   가: 우리 내일 같이 저녁 먹을까요? តើថ្ងៃស្អែកពួកយើងអាចហូបបាយល្ងាចជាមួយគ្នាបានដែរឬទេ?
   나: 좋아요. 같이 저녁 먹어요. ល្អ។ ថ្ងៃស្អែកអាចហូបបាយល្ងាចជាមួយគ្នាបាន។

   ① 식사 ② 운동 ③ 약속 ④ 쇼핑

2. 두 사람은 오늘 같이 무엇을 합니까? តើថ្ងៃនេះអ្នកទាំង២ធ្វើអ្វីជាមួយគ្នា?

   가: 우리 오늘 뭐 할까요? 같이 영화 볼까요?
   តើថ្ងៃនេះពួកយើងនឹងធ្វើអ្វី? មើលភាពយន្តជាមួយគ្នាល្អដែរឬទេ?
   나: 산책 어때요? 공원에서 같이 산책하고 싶어요.
   ពួកយើងដើរលំហែទៅយ៉ាងម៉េចដែរ? ខ្ញុំចង់ដើរលេងតាមសួនច្បារជាមួយគ្នាវិញ។
   가: 그래요? 좋아요. 그럼 산책해요. អញ្ចឹងឬ? ល្អ។ អញ្ចឹងដើរលំហែក៏បានដែរ។

   ① 책을 봅니다. ② 산책을 합니다. ③ 영화를 봅니다. ④ 게임을 합니다.



ចាប់ពីសំណួរទី៣ដល់ទី៥ គឺជាការជ្រើសរើសពាក្យដែលត្រឹមត្រូវដើម្បីបំពេញចន្លោះ។ សូមរំលឹកអំពីអ្វីដែលអ្នកបានរៀនរួចហើយមកនោះបណ្ដើរ និងធ្វើការដោះស្រាយសំណួរបណ្ដើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3. 수루 씨, 오늘 저녁에 ________ 있어요? ស៊ូរូ, តើល្ងាចនេះមានពេលទំនេរដែរឬទេ?

   ① 시간 ② 생일 ③ 날짜 ④ 주말

4. 우리 ________ 영화를 볼까요? 코미디 영화 어때요?
   តើពួកយើងនឹងមើលភាពយន្តបែបអ្វី? ភាពយន្តបែបកំប្លែងយ៉ាងម៉េចដែរ?

   ① 언제 ② 무슨 ③ 누구 ④ 무엇

5. 저는 내일 친구하고 같이 영화를 ____________. នៅថ្ងៃស្អែក ខ្ញុំចង់មើលភាពយន្តជាមួយមិត្តភក្តិ។

   ① 보세요 ② 봤어요 ③ 봐 주세요 ④ 보고 싶어요

정답 1. ③ 2. ② 3. ① 4. ② 5. ④



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~4] 빈칸에 들어갈 알맞은 말을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1. 저는 이번 주말에 ________이 많습니다. 고향 친구들과 영화도 보고 회사 동료들과 저녁도 먹을 겁니다.

ខ្ញុំមានការសន្យាណាត់ជួបជាច្រើននាចុងសប្តាហ៍នេះ។ ខ្ញុំនឹងទៅមើលភាពយន្តជាមួយមិត្តភក្តិដែលមកពីស្រុកកំណើតជាមួយគ្នា ហើយក៏ទៅហូបបាយល្ងាចជុំគ្នាជាមួយនឹងមិត្តរួមការងារផងដែរ។

① 배달　② 예약　③ 약속　④ 주문

2. 저는 주말에 ________이/가 있으면 보통 청소와 빨래를 하고 동료들과 영화를 봅니다.

នៅចុងសប្តាហ៍ប្រសិនបើមានពេល ជាធម្មតាខ្ញុំតែងតែបោសសម្អាតផ្ទះនិងបោកគក់ខោអាវ ហើយទៅមើលភាពយន្តជាមួយមិត្តរួមការងារ។

① 교육　② 시간　③ 야근　④ 회의

3. 집이 너무 ________ 출퇴근 시간이 많이 걸립니다. 그래서 다음 달에 회사 근처로 이사를 하려고 합니다.

ដោយសារតែផ្ទះនៅឆ្ងាយពេក ខ្ញុំត្រូវចំណាយពេលវេលាច្រើនណាស់ក្នុងការធ្វើដំណើរទៅមកក្រុមហ៊ុន។ ហេតុនេះហើយ នៅខែក្រោយខ្ញុំមានបំណងចង់រើផ្ទះមកនៅក្បែរក្រុមហ៊ុនវិញ។

① 멀어서　② 좋아서　③ 가까워서　④ 괜찮아서

4. 저는 월요일부터 금요일까지 일을 하고 주말에는 쉽니다. 오늘은 쉬는 날이지만 일이 ________ 공장에 나왔습니다.

ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រជាថ្ងៃដែលខ្ញុំធ្វើការ ចំណែកឯថ្ងៃចុងសប្តាហ៍វិញជាថ្ងៃឈប់សម្រាក។ ទោះបីថ្ងៃនេះជាថ្ងៃឈប់សម្រាកយ៉ាងណាក្តី ដោយហេតុថានៅរោងចក្រមានការងារច្រើនពេក ខ្ញុំត្រូវមកធ្វើការ។

① 편해서　② 적어서　③ 많아서　④ 한가해서

정답 1. ③ 2. ② 3. ① 4. ③

## 발음 ការបញ្ចេញសម្លេង

P-04

### សូមស្តាប់ដោយយកចិត្តទុកដាក់ រួចចូរថាតាម។

នៅក្នុងភាសាកូរ៉េ ‘ㄴ’, ‘ㅁ’, ‘ㅇ’ ជាការបញ្ចេញសម្លេងចេញពីច្រមុះ។ ក្នុងនោះដែរ ‘ㅇ’ វិញ លុះត្រាតែប្រកបជាមួយព្យញ្ជនៈ ឬក៏ស្រៈមួយផ្សេងទៀត ទើបអាចបញ្ចេញសម្លេងបាន។

(1) 나, 니, 누, 네, 노
(2) 누구, 누나, 나비, 나무, 노래
(3) 모두, 머리, 모자, 매미, 미나리
(4) 강, 공, 상, 방, 가방